

# ឃឹនសុខ (១៩៤២-២០១១)

*កើត នៅ ភូមិ ព្រែកតាទែន ស្រុកពញាឮ ក្នុង ខេត្រ កណ្ដាលនាឆ្នាំ១៩៤២។ ឃឹនសុខបានចាកលោកនេះនាព្រឹកថ្ងៃ ចន្ទទី១០ខែតុលា២០១១ក្នុងមន្ទីរពេទ្យក្លាម៉ារ នៅ ជាយ ក្រុង ប៉ារីសប្រទេសបារាំង។ ពិធីឈាបនកិច្ច នៅថ្ងៃសុក្រទី១៤ ខែ តុលា២០១១នាម៉ោង១រសៀលនៅ ក្លាម៉ារ* (108, rue Porte de Trivaux, 92140 Clamart)។

## ១)*សញ្ញាប័ត្រដែលបានទទួល*

- *មធ្យមសិក្សាប័ត្រទី២ផ្នែកគណិតវិទ្យា(ភ្នំពេញ១៩៦៣)*;
- *សញ្ញាប័ត្រសាស្ត្រាចារ្យមធ្យមសិក្សាបឋមភូមិផ្នែករូបវិទ្យា* (១៩៦៤);
- *បរិញ្ញាប័ត្រប្រវត្តិអរិយធម៌នៅមហាវិទ្យាល័យអក្សរសាស្ត្រ និងមនុស្សសាស្ត្រក្រុងភ្នំពេញ(១៩៦៧)*;

- សញ្ញាប័ត្រនៃសាលាវិជ្ជាជាន់ខ្ពស់ប្រវត្តិវិទ្យានិងនិរុត្តិវិទ្យា (Ecole Pratique des Hautes Etudes Ive Section) សកលវិទ្យាល័យស៊ក់បោន (១៩៧១);
- សញ្ញាប័ត្របណ្ឌិតប្រវត្តិសាស្ត្រនៅសកលវិទ្យាល័យប៉ារីសទី៤ (Université Paris IV) នាឆ្នាំ១៩៧៥;
- សញ្ញាប័ត្របណ្ឌិតរដ្ឋផ្នែកប្រវត្តិសាស្ត្រនិងជាតិពន្ធុវិទ្យានៅសាលាជាន់ខ្ពស់ខាងវិទ្យាសាស្ត្រសង្គមក្រុងប៉ារីស (Ecole des Hautes Etudes en Sciences Sociales) នាឆ្នាំ១៩៨៧;
- គុណវុឌ្ឍិខាងមុខងារជាសាស្ត្រាចារ្យនៃសកលវិទ្យាល័យ (ផ្នែក១៥)។

## ២)តំណែងក្នុងសិក្សាធិការ

- សាស្ត្រាចារ្យរូបវិទ្យានៅមហាវិទ្យាល័យបច្ចេកទេសនិងមុខរបរ(១៩៦៤-១៩៦៧);

- សាស្ត្រាចារ្យប្រវត្តិវិទ្យានៅមហាវិទ្យាល័យអក្សរសាស្ត្រ និងមនុស្សសាស្ត្រពី ឆ្នាំ១៩៦៨ដល់១៩៧៣;

- សាស្ត្រាចារ្យនៅវិទ្យាស្ថានភាសានិងអរិយធម៌បូព៌ាប្រទេស (Institut National des Langues et Civilisations orientales) ក្រុងប៉ារីសពីឆ្នាំ១៩៧៣រហូតដល់លោកចូលនិវត្តន៍។
- សមាជិកពរជបណ្ឌិតសភាកម្ពុជា។

### ៣)កិច្ចការរក្សានិងការពារវប្បធម៌ខ្មែរ

- នៅប្រទេសបារាំងពីឆ្នាំ១៩៨១ដល់២០០៦លោកបានបង្រៀនកូន ខ្មែរឱ្យចេះនិយាយ ខ្មែរ ឱ្យស្គាល់វប្បធម៌ខ្មែរ។

-នៅពេលរដូវវិស្សមកាលលោកបានចំណាយថវិកាផ្ទាល់ខ្លួនដើម្បីមទៅជួយបង្រៀនកូនខ្មែរនៅជំរំជនភៀសខ្លួន «បង្រៀនសាស្ត្រាចារ្យប្រវត្តិសាស្ត្រថ្នាក់មធ្យមសិក្សានៅភ្នំពេញ ទាំងទ្រឹស្តី និងទាំងដឹកនាំទស្សនកិច្ចសិក្សាទៅតាមទីតាំងប្រវត្តិសាស្ត្រនានានៅខេត្តសៀមរាប, និងបង្រៀននិស្សិតមន្ត្រីរាជការនៅសាលាភូមិន្ទរដ្ឋបាលជាដើម។[1]

-ជា ពិសេសទៅទៀត លោកបានចំណាយថវិកាផ្ទាល់ខ្លួនកសាងស្ពានបេតុងមួយនៅភូមិកំណើតសម្រាប់បម្រើប្រយោជន៍សាធារណៈផងដែរ។

### ៤)ការបោះពុម្ពផ្សាយជាសៀវភៅ

---

[1] ឃឹនសុខ.ឯកសារស្តីពីវគ្គបំប៉នគ្រូមធ្យមសិក្សាទុតិយភូមិឯកទេសប្រវត្តិវិទ្យា និងអក្សរសាស្ត្រខ្មែររាជធានីភ្នំពេញ,ឧបត្ថម្ភថវិកាដោយសម្តេច**ហ៊ុនសែន**នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជានិងឯកឧត្តម**ជាសុផារ៉ា**អតីតប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ, ភ្នំពេញ, ២០០១, ១០០ទំព័រ។

- *Chroniques royales du Cambodge (de Baññ Yāt à la prise de Laṅvaek de 1417 à 1595). Traduction française avec comparaison des différences version et introduction*. Publications. de l'EFEO, Collection de textes et documents sur l'Indochine, XIII, 1988, 471 p.
- *Le Cambodge entre le Siam et le Vietnam (de 1775 à 1860)*, Publications de l'EFEO, Collection de textes et documents sur l'Indochine, XVIII, 1991, 350 p. + cartes.
- *La grammaire du khmer moderne. វេយ្យាករណ៍ភាសាខ្មែរ.*

  Préface de Claude Hagère, professeur au Collège de France, Paris, Editions YOU-FENG, 1999,620 p.
- *Manuel de khmer*, vol. I, *សៀវភៅរៀនខ្មែរ, ភាគ១*, Paris,

  Editions YOU-FENG, 2000, 305 p.
- *L'annexion du Cambodge par les Vietnamiens au XIXème siècle. D'après les deux poèmes du vénérable Bâtum Baramey Pich.* កំពប់តែអុងParis, Editions YOU-FENG, 2002,

  416 p.
- En collaboration avec Claude JACQUES et Yoshiaki ISHIZAWA, Manuel d'épigraphie du Cambodge, Vol. I, Paris, EFEO/UNESCO, avec le concours du Gouvernement du Japon, 2007, 215 p.
- *វេយ្យាករណ៍ខ្មែរភ្នំពេញ*, ផ្សាយរបស់រាជបណ្ឌិតសភា,

  ២០០៧, ៥០១ទំព័រៗ
- វិភាគទានក្នុងសៀវភៅរួមនិងអត្ថបទសិក្សាសូមអានគន្ថនិ

  ទេសក្នុងស៊ីតវេប៖

http://aefek.free.fr/travaux/




ឃឹនសុខអង្គុយនៅជួរទី១មនុស្សទី៣ពីឆ្វេងទៅស្តាំ(ជំនាន់និស្សិតវេយ្យណ៍
និងនិរុត្តិវិទ្យាថតជាមួយព្រះភិក្ខុប៉ាងខាត់នៅមុខសកលវិទ្យាល័យ

សង្គម រាស្ត្រនិយមភ្នំពេញនាឆ្នាំ១៩៦៦)

ឃឹនសុខនិងអ៊ុចកិរម្យប្រធានមជ្ឈមណ្ឌលពុទ្ធិខ្មែរ នៅ

សហរដ្ឋអាមេរិក(២០០៦)




សន្និសីទនៅសាលាខ្មែរក្នុងក្រុងប៉ារីសទី១៣(វិច្ឆិកា២០១០)

រៀបរៀងដោយ

បណ្ឌិតសភាចារ្យ **ឃីង៉ហុកឌី**